# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ២៣៩,៦៩៦ ដុល្លារអាមេរិកដើម្បីកាត់បន្ថយភាពក្រីក្រ នៅតំបន់ជនបទតាមរយៈការបង្កើតនូវការគ្រប់គ្រងដែលមាននិរន្តរភាព ក្នុងសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង (SAC)



ក្រោមគ្រោងការណ៍នៃជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ¥ ១៩,៤១៥,៣៧៦ ស្មើនឹង២៣៩,៦៩៦ដុល្លារអាមេរិកដល់ក្រុមអ្នកស្ម័គ្រចិត្តអន្តរជាតិរបស់យ៉ាម៉ាហ្គាតា(អាយ.វី.វ៉ាយ)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយលោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រី អាយូមី ម៉ាត់ស៊ូរ៉ា នាយិកាអង្គការអាយ.វី.វ៉ាយ នៅស្ថានទូតជប៉ុន។



តាមរយៈគម្រោងនេះ អង្គការ អាយ.វី.វ៉ាយ នឹងជួយគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់សហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC)ដើម្បីសហគមន៍នេះមានលទ្ធភាពបន្តប្រតិបត្តិការដោយខ្លួនឯងប្រកបដោយនិរន្តរភាពនៅពេលគម្រោងនេះត្រូវបានបញ្ចប់។ជាពិសេសអាយ.វី.វ៉ាយនឹងផ្តល់ការបណ្តុះបណ្តាលជាច្រើនដល់SACដែលរួមមានជាអាទិ៍ ការដាំដុះបន្លែដែលមិនមានសារធាតុគីមី វិធីសាស្ត្រផ្សព្វផ្សាយជាសាធារណៈសម្រាប់ផលិតផលរបស់ពួកគេ ផែនការអាជីវកម្ម និង ការរក្សាទុកបញ្ជីគណនេយ្យជាដើម។ ជាងនេះទៅទៀត ប្រកសម្រាប់ដឹកជញ្ជូន និង ចែកចាយផលិតផលកសិកម្មរបស់ SAC ក៏នឹងត្រូវបានបង្កើតឡើងក្នុងគម្រោងនេះផងដែរ។ ដូច្នេះយើងរំពឹងថា SACនឹងក្លាយទៅជាសហគមន៍ផ្គត់ផ្គង់កសិផលគំរូមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្មវិធីជំនួយឥតសំណង សម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តារបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ១៧.៧ លានដុល្លារអាមេរិកដល់គម្រោងចំនួន ៦៩ គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និងសកម្មភាពបោសសំអាតមីន។ គម្រោងរបស់អង្គការអាយ.វី.វ៉ាយនេះគឺជាគម្រោង

ទី៥តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១២របស់ជប៉ុន(មេសា២០១២ដល់មិនា២០១៣)។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល:* *eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*